**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ១៣៩/០០២/២០០៨

ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៨

**សេចក្តីសម្រេច**

លេខ : ០៩៦/០០១/២០០៨ កបធ.ច

ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០០៨

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែ មករា ឆ្នាំ ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ៤៦១ រស ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៨ របស់សម្តេចអគ្គមហាពញា-ចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពលើអត្ថបទច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៨ នាសម័យប្រជុំរដ្ឋសភាលើកទី ៧ នីតិកាលទី ៣ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៨ វេលាម៉ោង ១៧ និង១០ នាទី ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភាបានអនុវត្តត្រឹមត្រូវតាមបែបបទ ដែលមានចែងក្នុងមាត្រា១១៣ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យ និង អនុម័តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- យល់ឃើញថា សំណើរបស់សម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្របនឹង មាត្រា ១៤០ថ្មី វាក្យខ័ណ្ឌទី២ នៃរដ្ឋធម្មនុញ្ញ និង មាត្រា១៦ ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពី ការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែ មករា ឆ្នាំ ២០០៧ ដូច្នេះក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួល យកសំណើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់នេះមកពិនិត្យបាន
- យល់ឃើញថា ទម្រង់នៃការតាក់តែងច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា នៅក្នុងគ្រប់មាត្រាទាំងអស់នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ពុំមានបទប្បញ្ញត្តិណាមួយផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ ។

## សម្រេច

**មាត្រា ១.** ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលរដ្ឋសភាបានអនុម័តនៅ ថ្ងៃ អង្គារ ទី ០១ ខែ មេសា ឆ្នាំ ២០០៨ នាសម័យប្រជុំរដ្ឋសភាលើកទី ៧ នីតិកាលទី ៣ ហើយ ដែលព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និង គតិច្បាប់ដោយឥតកែប្រែ ក្នុងសម័យប្រជុំពេញអង្គលើកទី ៤ នីតិកាលទី ២ នៃព្រឹទ្ធសភា នាថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៨ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២.** សេចក្ដីសម្រេចនេះធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០០៨ ក្នុងកិច្ចប្រជុំពេញអង្គ នៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្ដីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើ អំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០០៨

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**